unicef
for every child

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

លេខ 13 PR-21/EoJ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១

## ប្រទេសជប៉ុនផ្តល់ថវិកាដល់គម្រោងដើម្បីបញ្ចប់អំពើហិង្សាលើកុមារ អំឡុងពេលមានជំងឺរាតត្បាតកូវីដ១៩ ក្នុងប្រទេសកម្ពុជា

ទោះបីជាកុមារប្រឈមនឹងហានិភ័យសុខភាពពីជំងឺកូវីដ១៩ តិចជាងមនុស្សពេញវ័យក៏ដោយ ក៏មានរបាយការណ៍សាកលមួយចំនួនបានបង្ហាញថា កុមារអាចនឹងមានហានិភ័យខ្ពស់ក្នុងការទទួលរងនូវអំពើហិង្សាដែលបណ្តាលមកពីជំងឺរាតត្បាតនេះ។ ការរឹតត្បិតលើការធ្វើដំណើរ ការបាត់បង់ប្រាក់ចំណូល ភាពឯកោ កន្លែងរស់នៅចង្អៀត និងកម្រិតខ្ពស់នៃភាពតានតឹង និងជំងឺថប់បារម្ភ ធ្វើឲ្យមានការកើនឡើងនូវលទ្ធភាពដែលកុមារអាចជួបប្រទះ និងទទួលរងការរំលោភបំពានលើរាងកាយ និងផ្លូវចិត្តនៅផ្ទះ។ ជាការឆ្លើយតប រដ្ឋាភិបាលជប៉ុន និងយូនីសេហ្វ កំពុងចាប់ផ្តើមគម្រោងថ្មីមួយឈ្មោះថា " ការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារនៅកម្ពុជា ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ និងការស្តារឡើងវិញ" ។

រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាចំនួន ៣៤០ 000 000 យេន (ប្រមាណជា ៣ ០៩០ ៩០៩ ដុល្លារអាមេរិក) ដល់យូនីសេហ្វសម្រាប់គម្រោងនេះ។ គោលបំណងរបស់គម្រោង គឺដើម្បីធានាថាកុមារា និងកុមារី នៅកម្ពុជាទទួលបានការការពារពីអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ១៩ និងការស្តារឡើងវិញ ដើម្បីពង្រឹងសន្តិសុខមនុស្សជាតិ។ សេវាកម្មកិច្ចការពារកុមារមួយចំនួនបានប្រឈមនឹងការរំខានក្នុងអំឡុងពេលមានជំងឺរាតត្បាត ដូច្នេះគម្រោងនេះមានគោលបំណងធានានូវការស្តារ និងការបន្តសេវាកម្មកិច្ចការពារទាំងនេះឡើងវិញ។

គម្រោងនេះនឹងបង្កើតនូវយុទ្ធសាស្ត្រ និងការអន្តរាគមន៍ដែលមានស្រាប់ដើម្បីពង្រឹងសេវាកម្មកិច្ចការពារកុមារដែលងាយរងគ្រោះខ្លាំង និងក្រុមគ្រួសាររបស់ពួកគេនៅទូទាំងប្រទេសកម្ពុជាក្នុង

អំឡុងពេលរាតត្បាតនៃជំងឺកូវីដ១៩ និងការស្តារឡើងវិញ ។ គម្រោងនេះនឹងគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើត និងអនុវត្តក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌគតិយុត្ត ដើម្បីលើកឡើងពីកត្តាហានិភ័យនានាដែលអាចកើតមានឡើងដោយសារជំងឺកូវីដ១៩ ទៅលើកិច្ចការពារកុមារ។ គម្រោងនេះក៏នឹងគាំទ្រដល់លោកគ្រូ អ្នកគ្រូ បុគ្គលិកសិក្សា ឪពុកម្តាយ និងអ្នកមើលថែទាំ ក្នុងការរៀនពីវិធីថ្មីៗដើម្បីបង្កើនចំណេះដឹង ឥរិយាបថ និងការអនុវត្តរបស់ពួកគេ ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ។

អ្វីដែលសំខាន់បំផុតនោះគឺគម្រោងនេះ នឹងធានាថាកុមាររងាយរងគ្រោះអាចទទួលបានសេវាកម្មការពារប្រកបដោយគុណភាពរួមមានការគ្រប់គ្រងករណី ការគាំទ្រសុខភាពផ្លូវចិត្ត និងការគាំទ្រផ្នែកចិត្តសាស្ត្រនិងសង្គម ជំនួយផ្នែកច្បាប់ និងសេវាសុខភាព។ ខ្សែបណ្តាញជំនួយ និងលេខទំនាក់ទំនងទាន់ហេតុការណ៍ នឹងត្រូវបានបង្កើនឡើងដើម្បីផ្តល់នូវបណ្តាញសុវត្ថិភាពដែលមានភាពងាយស្រួលទាក់ទងសម្រាប់កុមារ និងមនុស្សពេញវ័យដើម្បីរាយការណ៍អំពីអំពើហិង្សារួមទាំងការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពាន។ សុវត្ថិភាពរបស់កុមារតាមប្រព័ន្ធអ៊ិនធើណេត នឹងត្រូវបានលើកកម្ពស់តាមរយៈការពង្រឹងភាពជាដៃគូជាមួយឧស្សាហកម្មព័ត៌មាន និងបច្ចេកវិទ្យា (ICT) និងការលើកកម្ពស់ការយល់ដឹងនិងសកម្មភាពអប់រំសម្រាប់កុមារនិងអ្នកថែទាំ។ ជាចុងក្រោយ ការគ្រប់គ្រងទិន្នន័យ និងការបង្កើតភ័ស្តុតាង នឹងត្រូវបានពង្រឹងតាមរយៈការធ្វើឱ្យប្រសើរឡើងនូវរបាយការណ៍ និងគុណភាពនៃទិន្នន័យដែលទាក់ទងនឹងអំពើហិង្សាលើកុមារ។

គោលដៅចុងក្រោយនោះគឺការគាំទ្ររាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតប្រព័ន្ធការពារកុមារដែលមានការសម្របសម្រួលសមស្រប និងប្រកបដោយចីរភាពដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបង្កឡើងកាន់តែខ្លាំងដោយសារជំងឺកូវីដ១៩ ក្រោមកិច្ចសហការជាមួយអង្គការសង្គមស៊ីវិល (CSOs) និងដៃគូពាក់ព័ន្ធដទៃទៀត។

លោកស្រីហ្វ័រហ្គ ហ្វយូហ្សិច នាយិកាយូនីសេហ្វប្រចាំកម្ពុជាបានមានប្រសាសន៍ថា "រាល់ទម្រង់នៃអំពើហិង្សាដែលកុមារបានជួបប្រទះអាចបណ្តាលឲ្យមានផលវិបាកធ្ងន់ធ្ងរ និងពេញមួយជីវិត ហើយយើងមានការព្រួយបារម្ភយ៉ាងខ្លាំង ដែលពួកគេអាចមានហានិភ័យខ្ពស់ក្នុងការទទួលរងនូវអំពើហិង្សានិងការរំលោភបំពានក្នុងអំឡុងពេលដ៏លំបាកនៃជំងឺរាតត្បាតកូវីដ១៩"។ លោកស្រីបានបន្តថា "យើងសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលជប៉ុន ដែលបានចូលរួមចំណែកយ៉ាងសំខាន់ និងទាន់ពេលវេលា។ គម្រោងនេះមានគោលបំណងពង្រឹងប្រព័ន្ធ និងសេវាកម្មកិច្ចការពារកុមារ និងចូលរួម

ចំណែកសម្រេចឲ្យបាននូវ សិទ្ធិលូតលាស់របស់កុមារកម្ពុជា នៅក្នុងបរិស្ថានប្រកបដោយសុវត្ថិភាព និងកិច្ចការពារ។”

ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពជប៉ុនប្រចាំកម្ពុជាបានមានប្រសាសន៍ថា “អំពើហិង្សាក្នុងវ័យកុមារភាព អាចបង្កគ្រោះថ្នាក់ជាច្រើនដល់កុមារ និងពេញមួយជីវិតរបស់ពួកគេ។ ការទទួលរងគ្រោះនូវអំពើហិង្សានៅវ័យកុមារភាព ជារឿយៗនាំឲ្យមានផលអវិជ្ជមានខាងអាកប្បកិរិយា ផ្លូវចិត្តនិងរាងកាយនៅក្នុងវ័យជំទង់ និងពេញវ័យដែលជាបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ”។ ឯកឧត្តមបានបន្តទៀតថា “យូនីសេហ្វ មានសកម្មភាពនៅកម្ពុជាតាំងពីឆ្នាំ ១៩៥២ និងមានបទពិសោធលេចធ្លោរក្នុងការធ្វើការដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។ នេះជាមូលហេតុដែលរដ្ឋាភិបាលជប៉ុនចាត់ទុកយូនីសេហ្វ ជាដៃគូដែលគួរឲ្យទុកចិត្តបំផុតដើម្បីសម្រេចគោលដៅនេះ។ រដ្ឋាភិបាលជប៉ុន និងយូនីសេហ្វប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីបញ្ចប់អំពើហិង្សាលើកុមារហើយនឹងបន្តរហូតដល់យើងបានជួយបង្កើតពិភពលោកមួយដែលគ្មានកុមារណាម្នាក់ត្រូវបានទុកចោល។ យើងនឹងបន្តសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីជួយស្តារប្រទេសឡើងវិញពីជំងឺកូវីដ ១៩ ។

---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣ ២១៧ ១៦១, ទូរសារ៖ ០២៣ ២១៦ ១៦២*

*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*

*គេហទំព័រ៖ [http://www.kh.emb-japn.go.jp](http://www.kh.emb-japn.go.jp)*

*ទំនាក់ទំនងយូនីសេហ្វកម្ពុជា*

*អ្នកស្រី រូឌីណា វ៉ូវ៉ូដា ប្រធានផ្នែកទំនាក់ទំនង*

*ទូរសព្ទ៖ +៨៥៥ ២៣ ២៦០ ២០៤ ext=៤៣៤*

*សារអេឡិកត្រូនិក៖ [rvojvoda@unicef.org](mailto:rvojvoda@unicef.org)*

*លោក មាស ប៊ុនលី មន្ត្រីជំនាញផ្នែកទំនាក់ទំនង*

*ទូរសព្ទ៖ +៨៥៥ ២៣ ២៦០ ២០៤ ext=៤៣៥*

*សារអេឡិកត្រូនិក៖ [bmeas@unicef.org](mailto:bmeas@unicef.org)*